ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤៧

ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

សំណុំរឿងជំនុំជម្រះលេខៈ ៣៨០

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣

សាលក្រមព្រហ្មទណ្ឌលេខៈ ៧៣ "ខ"

ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តតាកែវ បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០២:៣០នាទីរសៀល ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូង ជាប្រធានក្រុមប្រឹក្សា

លោក [redacted] អនុប្រធានសាលាដំបូង ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខៈ ១៤៧ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.នាមត្រកូល [redacted] នាមខ្លួន **ចាន់វាសនា** ហៅ **ស្នា** ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] អ៊ិន (ស) ម្តាយឈ្មោះ [redacted]សាឡុន (រ) ប្រពន្ធឈ្មោះ [redacted] ណារី (លែងលះ) មានកូន២នាក់ ជានីតិជន ទោសពីមុនគ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ១២៣ ត.ព្រ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣។

ជាប់ចោទពីបទៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.នាមត្រកូល [redacted] នាមខ្លួន **ទុំ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ទូន (ស) ម្តាយឈ្មោះ [redacted] រ៉េត (រ) ប្រពន្ធឈ្មោះ [redacted] ឡៃហួយ (រ) មានកូន១នាក់ ជានីតិជន ទោសពីមុនគ្មាន។

ជាប់ចោទពីបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.នាមត្រកូល [redacted] នាមខ្លួន **ថារដ្ឋ** ហៅ **ទុន** ភេទប្រុស អាយុ១៥ឆ្នាំ (កើតឆ្នាំ២០០៨) ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] រដ្ឋា (ស) ម្តាយឈ្មោះ [redacted] ពុំសែន (រ) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ២៩២ ដ.ស.ព/២៣ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញដីកាដំណោះស្រាយលេខៈ ២៨៨ ដ.ដ.រ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង២១ និង២០នាទីយប់ កម្លាំងនគរបាលអន្តរាគមន៍ នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បានចុះបង្ក្រាបករណី ជួញដូរ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅចំណុចភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ បានធ្វើការឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា ភេទប្រុស អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] ទុំ ភេទប្រុស អាយុ២៨ឆ្នាំ ព្រមទាំងដកហូតវត្ថុតាងដូចជាៈ ម្សៅក្រាមពណ៌សថ្លាចំនួន ១កញ្ចប់តូច ទម្ងន់០,២២ក្រាម និងម៉ូតូចំនួន ១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពាក់ស្លាកលេខ ភ្នំពេញ 1AE-4741។ ក្រោយពីធ្វើការសាកសួរជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ស្នា បានឆ្លើយសារភាពថា ថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាននោះ គឺជារបស់ខ្លួនដែលបានទិញមកពីឈ្មោះ ទុន ភេទប្រុស អាយុប្រហែល ២៧ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា ដោយទិញកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣។ ចំណែកជនជាប់ចោទឈ្មោះ [redacted] ទុំ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន ប៉ុន្តែខ្លួនពុំដែលបានជួញដូរ ឬចែកចាយថ្នាំញៀននោះទេ ហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាននោះ គឺមិនមែនជារបស់ខ្លួនទេ គឺជារបស់ឈ្មោះ [redacted] ចាន់វាសនា ហៅ ស្នា។ ក្រោយចប់ការសាកសួរ សមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តតាកែវ ចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ចាន់វាសនា** បានឆ្លើយថាៈ នៅថ្ងៃកើតហេតុវេលាម៉ោង១៧ល្ងាច ខ្ញុំជួយសែងទូកជាមួយឈ្មោះ [redacted] ទុំ រួចឈ្មោះ [redacted] ទុំ បបួលខ្ញុំថា ចង់រកអីជក់មេបន្តិច ព្រោះល្ងាចនេះទៅរកត្រី ហើយក៏ឯកភាពគ្នាទៅទិញថ្នាំញៀន ពេលនោះឈ្មោះ [redacted] ទុំ ជិះម៉ូតូឌុបខ្ញុំទៅទិញថ្នាំញៀននៅខាងជើងវត្តខ្សឹង ដោយទិញពីឈ្មោះ ទុន នៅតាមផ្លូវ តម្លៃ ១៥,០០០៛ ពេលទៅដល់ខ្ញុំសួរឈ្មោះ ទុន ថា មានអីវ៉ាន់អត់ខ្ញុំទិញ ១៥,០០០៛។ ក្រោយទិញថ្នាំញៀនរួចខ្ញុំជាអ្នកទុក ហើយជិះម៉ូតូត្រលប់មកផ្ទះវិញ ក៏ជួបសមត្ថកិច្ចនៅតាមផ្លូវ ខ្ញុំចុះពីលើម៉ូតូយកថ្នាំញៀនបោះចោលក្បែរមាត់ទឹក តែត្រូវសមត្ថកិច្ចរកឃើញថ្នាំញៀនក៏ឃាត់ខ្លួនខ្ញុំ និងឈ្មោះ [redacted] ទុំ តែម្តង។ ខ្ញុំទទួលស្គាល់ថ្នាំញៀនដែលសមត្ថកិច្ចដកហូតនេះ គឺជារបស់ខ្ញុំដែលបានទិញពីឈ្មោះ ទុន។ ម្តាយរបស់ឈ្មោះ ទុន ឈ្មោះ សែន ឪពុកស្លាប់។ ឈ្មោះ ទុន មិនមែនអាយុ១៥ឆ្នាំទេ គ្រាន់តែវាមានលក្ខណៈក្រិន។ ខ្ញុំចេះប្រើប្រាស់ថ្នាំញៀនជាង១ឆ្នាំមកហើយ គឺប្រើប្រាស់ជាមួយឈ្មោះ [redacted] ទុំ ម្នាក់ប៉ុណ្ណោះ។ ខ្ញុំទិញថ្នាំញៀន១ដង១កញ្ចប់ សម្រាប់ប្រើប្រាស់ជាមួយឈ្មោះ [redacted] ទុំ ខ្ញុំប្រើប្រាស់ពុំដែលសល់ទេ។ ខ្ញុំទិញថ្នាំញៀនសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ ពុំមានគោលបំណងទិញសម្រាប់លក់បន្តទេ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ទុំ បានឆ្លើយថា: នៅថ្ងៃកើតហេតុវេលាម៉ោង៧យប់ មុនដំបូងខ្ញុំរកឈ្មោះ ស្នា ឱ្យជួយសែងទូក ពេលសែងទូករួចខ្ញុំបបួលគាត់ទៅទិញថ្នាំញៀនដើម្បីប្រើប្រាស់ ហើយខ្ញុំឌុបឈ្មោះ ស្នា ទៅទិញថ្នាំញៀនដោយជិះម៉ូតូរបស់ខ្ញុំ។ ខ្ញុំឱ្យលុយទៅឈ្មោះ ស្នា ចំនួន ១៥,០០០៛ នៅតាមផ្លូវ។ ពួកខ្ញុំទិញថ្នាំញៀនពីឈ្មោះ ទុន ភេទប្រុស អាយុប្រហែល២៤ ទៅ ២៥ឆ្នាំ ពុំមែនអាយុ១៥ឆ្នាំទេ។ ពេលទៅដល់កន្លែងទិញថ្នាំញៀន ឈ្មោះ ស្នា ជាអ្នកចុះទៅទិញថ្នាំញៀន។ ក្រោយពីបានថ្នាំញៀនខ្ញុំជិះម៉ូតូត្រលប់មកផ្ទះវិញ ក៏ត្រូវសមត្ថកិច្ចឃាត់សួរតាមផ្លូវ ហើយឈ្មោះ ស្នា បោះថ្នាំញៀនចោល តែត្រូវសមត្ថកិច្ចរកឃើញវិញ ហើយក៏ឃាត់ខ្លួនពួកខ្ញុំទាំងពីរនាក់តែម្តង ហើយតុលាការបានឱ្យខ្ញុំទៅផ្ទះវិញ។ ខ្ញុំពិតជាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន។ កន្លងមកខ្ញុំជក់ថ្នាំញៀននៅផ្ទះ ជួលកាលជក់ថ្នាំញៀននៅក្នុងព្រៃ។ ម៉ូតូជារបស់ខ្ញុំ សព្វថ្ងៃខ្ញុំមិនទាន់បានម៉ូតូយកទៅប្រើប្រាស់វិញទេ។

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា**

ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ទុំ និងឈ្មោះ [redacted] ចាន់វាសនា បានឆ្លើយសារភាពដូចបទចោទប្រាកដមែន។ ហេតុនេះ តំណាងអយ្យការសុំរក្សាបទចោទដដែល និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចទៅតាមច្បាប់។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមសវនាការនៅថ្ងៃនេះឃើញថា កូនក្តីខ្លួនបានទិញថ្នាំញៀន គឺពោលគោលបំណងយកមកជក់ប៉ុណ្ណោះ ហើយជក់តែ១ដងអស់ហើយ ចំពោះឈ្មោះ [redacted] ទុំ សុំឱ្យក្រុមប្រឹក្សាដាក់ទោសអប្បបរមា ដោយព្យួរទោសសាកល្បង ហើយឈ្មោះ [redacted] ចាន់វាសនា សុំឱ្យតុលាការផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសុំឱ្យមានសិទ្ធិសេរីភាពវិញ។ ចំពោះម៉ូតូសុំឱ្យតុលាការប្រគល់ឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ទុំ វិញ។ ចំពោះឈ្មោះ សៅសែន ថារដ្ឋ សុំឱ្យតុលាការពិនិត្យទៅលើមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់វាសនា** បានសំណូមពរថា សូមឱ្យតុលាការជួយសម្រាលទោសផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ទុំ បានសំណូមពរថា សូមតុលាការកុំផ្តន្ទាទោសខ្លួនធ្ងន់ពេក។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១.កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ថិតនៅភូមិឡឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ពិតជាមានករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា ហៅ ស្នា, ករណី ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ



Scanned with CamScanner

[redacted]ទុំ និងករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ ហៅ ទុន ប្រាកដមែន។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា បានឆ្លើយថា: នៅថ្ងៃកើតហេតុវេលាម៉ោង១៧ល្ងាច ខ្លួនជួយសែងទូកជាមួយឈ្មោះ [redacted] ទុំ រួចឈ្មោះ [redacted] ទុំ បបួលខ្លួនថា ចង់រកអីជកមេបន្តិច ព្រោះល្ងាចនេះទៅរកត្រី ហើយក៏ឯកភាពគ្នាទៅទិញថ្នាំញៀន ពេលនោះឈ្មោះ [redacted] ទុំ ជិះម៉ូតូឌុបខ្លួនទៅទិញថ្នាំញៀននៅខាងជើងវត្តខ្សឹង ដោយទិញពីឈ្មោះ ទុន នៅតាមផ្លូវ តម្លៃ ១៥,០០០៛ ពេលទៅដល់ខ្លួនសួរឈ្មោះ ទុន ថា មានអីវ៉ាន់អត់ខ្លួនទិញ ១៥,០០០៛។ ក្រោយទិញថ្នាំញៀនរួចខ្លួនជាអ្នកទុក ហើយជិះម៉ូតូត្រលប់មកផ្ទះវិញ ក៏ជួបសមត្ថកិច្ចនៅតាមផ្លូវ ខ្លួនចុះពីលើម៉ូតូយកថ្នាំញៀនបោះចោលក្បែរមាត់ទឹក តែត្រូវសមត្ថកិច្ចរកឃើញថ្នាំញៀនក៏ឃាត់ខ្លួន និងឈ្មោះ [redacted] ទុំ តែម្តង។ ខ្លួនទទួលស្គាល់ថ្នាំញៀនដែលសមត្ថកិច្ចដកហូតនេះ គឺជារបស់ខ្លួនដែលបានទិញពីឈ្មោះ ទុន។ ម្តាយរបស់ឈ្មោះ ទុន ឈ្មោះ សែន ឪពុកស្លាប់។ ឈ្មោះ ទុន មិនមែនអាយុ១៥ឆ្នាំទេ គ្រាន់តែវាមានលក្ខណៈក្រិន។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនជាង១ឆ្នាំមកហើយ គឺប្រើប្រាស់ជាមួយឈ្មោះ [redacted] ទុំ ម្នាក់ប៉ុណ្ណោះ។ ខ្លួនទិញថ្នាំញៀន១ដង ១កញ្ចប់ សម្រាប់ប្រើប្រាស់ជាមួយឈ្មោះ [redacted] ទុំ ខ្លួនប្រើប្រាស់ពុំដែលសល់ទេ។ ខ្លួនទិញថ្នាំញៀនសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ ពុំមានគោលបំណងទិញសម្រាប់លក់បន្តទេ។ ចម្លើយសារភាពរបស់ជនជាប់ចោទនេះ អាចឲ្យតុលាការជឿជាក់បានថា ជនជាប់ចោទ បានប្រព្រឹត្តអំពើ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទុំ បានឆ្លើយថា: នៅថ្ងៃកើតហេតុវេលាម៉ោង៧យប់ មុនដំបូងខ្លួនរកឈ្មោះ ស្នា ឲ្យជួយសែងទូក ពេលសែងទូករួចខ្លួនបបួលគាត់ទៅទិញថ្នាំញៀនដើម្បីប្រើប្រាស់ ហើយខ្លួនឌុបឈ្មោះ ស្នា ទៅទិញ ថ្នាំញៀនដោយជិះម៉ូតូរបស់ខ្លួន។ ខ្លួនឲ្យលុយទៅឈ្មោះ ស្នា ចំនួន ១៥,០០០៛ នៅតាមផ្លូវ។ ពួកខ្លួនទិញថ្នាំញៀនពីឈ្មោះ ទុន ភេទប្រុស អាយុប្រហែល២៤ ទៅ ២៥ឆ្នាំ ពុំមែនអាយុ១៥ឆ្នាំទេ។ ពេលទៅដល់កន្លែងទិញថ្នាំញៀនឈ្មោះ ស្នា ជាអ្នកចុះទៅទិញថ្នាំញៀន។ ក្រោយពីបានថ្នាំញៀនខ្លួនជិះម៉ូតូត្រលប់មកផ្ទះវិញ ក៏ត្រូវសមត្ថកិច្ចឃាត់សួរតាមផ្លូវ ហើយឈ្មោះ ស្នា បោះថ្នាំញៀនចោល តែត្រូវសមត្ថកិច្ចរកឃើញវិញ ហើយក៏ឃាត់ខ្លួនពួកខ្លួនទាំងពីរនាក់តែម្តង ហើយតុលាការបានឲ្យខ្លួនទៅផ្ទះវិញ។ ខ្លួនពិតជាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន។ កន្លងមកខ្លួនជក់ថ្នាំញៀននៅផ្ទះ ជួលកាលជក់ថ្នាំញៀននៅក្នុងព្រៃ។ ម៉ូតូជារបស់ខ្លួន សព្វថ្ងៃខ្លួនមិនទាន់បានម៉ូតូយកទៅប្រើប្រាស់វិញទេ។ ចម្លើយសារភាពរបស់ជនជាប់ចោទនេះ អាចឲ្យតុលាការជឿជាក់បានថា ជនជាប់ចោទ បានប្រព្រឹត្តអំពើ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៤.ជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ ក្រោយពីប្រព្រឹត្តបទល្មើសរួចបានរត់គេចខ្លួនបាត់។ ការរត់គេចខ្លួន និងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ប៊ុន ចាន់វាសនា និងឈ្មោះ ម៉ែន ទុំ បង្ហាញឲ្យឃើញថា ជនជាប់ចោទឈ្មោះ សៅសែន ថារដ្ឋ ហៅ ទុន ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការ ប្រាកដមែន។

៥.ជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា និងឈ្មោះ [redacted] ទុំ ជានីតិជន និងជាសមត្ថជន ដែលមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។

៦.ជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ ហៅ ទុន ជាអនីតិជនដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌបាន ពោលគឺជនជាប់ចោទពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទ



Scanned with CamScanner

ពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។ ដូចនេះគប្បីតុលាការ ពិចារណាទៅលើរបបប្រកាសទោសតាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

៧.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់ហាមឃាត់តាមមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ទុំ បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់ហាមឃាត់តាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់ហាមឃាត់តាមមាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា, ឈ្មោះ [redacted] ទុំ និងឈ្មោះ [redacted] ថារដ្ឋ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

១១.ជនជាប់ចោទឈ្មោះ [redacted] ទុំ ទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ ដូចនេះគប្បីតុលាការ ពិចារណាទៅលើរបបប្រកាសទោសពាក់ព័ន្ធជាមួយការព្យួរទោសតាមបញ្ញត្តិមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

១២.តាមកំណត់ហេតុធ្វើតេស្តទឹកនោមលេខៈ ២៣/១៣ ក.ណ.ហ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ និងលេខៈ ២៣/១៤ ក.ណ.ហ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន តាមកំណត់ហេតុជាលទ្ធផល វិជ្ជមាន មានផ្ទុកសារធាតុញៀនក្នុងខ្លួន បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា និងឈ្មោះ [redacted] ទុំ ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

១៣.តាមកំណត់ហេតុធ្វើតេស្តជំហានដំបូងលេខៈ ២៣/១៦ ក.ណ.ហ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន តាមកំណត់ហេតុជាលទ្ធផល ពណ៌លឿងទុំ ការសន្និដ្ឋាន ជាប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ប្រាកដមែន។

១៤.តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ វត្ថុតាងរួមមាន៖

-គ្រឿងញៀនប្រភេទមេតំហ្វេតាមីន (Ice) ចំនួន០១កញ្ចប់ ទម្ងន់ 0,២២ក្រាម (សូន្យក្បៀសម្ភៃពីរក្រាម)។

**គប្បីតុលាការសម្រេចរឹបអូស និងបំផ្លាញចោល។**

-ម៉ូតូចំនួន០១គ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AE-4741។

**គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់វិញ។**

១៥.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាន់វាសនា ហៅ ស្នា ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

១៦.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ទុំ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពី ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៧.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចារដ្ឋ ហៅ ទុន ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពី ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៨.តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា ជនជាប់ចោទឈ្មោះ [redacted] ទុំ និងឈ្មោះ [redacted] ចាន់វាសនា បានឆ្លើយសារភាពដូចបទចោទប្រកាន់មែន។ ហេតុនេះ តំណាងអយ្យការសុំរក្សាបទចោទដដែល និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចទៅតាមច្បាប់។ ការស្នើសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ ព្រោះមានពិរុទ្ធភាពគ្រប់គ្រាន់ គប្បីតុលាការពិចារណា។

១៩.មេធាវីការពារសិទ្ធិឱ្យជនជាប់បានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងតាមសវនាការនៅថ្ងៃនេះឃើញថា កូនក្តីខ្លួនបានទិញថ្នាំញៀន គឺពោលគោលបំណងយកមកជក់ប៉ុណ្ណោះ ហើយជក់តែ១ដងអស់ហើយ ចំពោះឈ្មោះ [redacted] ទុំ សុំឱ្យក្រុមប្រឹក្សាដាក់ទោសអប្បបរមា ដោយព្យួរទោសសាកល្បង ហើយឈ្មោះ [redacted] ចាន់វាសនា សុំឱ្យតុលាការផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសុំឱ្យមានសិទ្ធិសេរីភាពវិញ។ ចំពោះម៉ូតូសុំឱ្យតុលាការប្រគល់ឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ទុំ វិញ។ ចំពោះឈ្មោះ [redacted] ចារដ្ឋ សុំឱ្យតុលាការពិនិត្យទៅលើមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការស្នើសុំនេះ គប្បីតុលាការពិចារណា។

**<u>ហេតុដូច្នេះសម្រេច</u>**

១/.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចាន់វាសនា** ហៅ **ស្លា** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០២ (**ពីរ**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៤,០០០,០០០៛ (បួនលាន) រៀល** ពីបទៈ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ទុំ** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៦ (ប្រាំមួយ) ខែ** ប៉ុន្តែទោសនេះត្រូវព្យួរ និងពិន័យជាប្រាក់ចំនួន **១,០០០,០០០៛ (មួយលាន) រៀល** ពីបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចារដ្ឋ** ហៅ **ទុន** ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០២ (**ពីរ**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៤,០០០,០០០៛ (បួនលាន) រៀល** ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៣/.វត្ថុតាងរួមមាន៖

-គ្រឿងញៀនប្រភេទមេតំហ្វេតាមីន (Ice) ចំនួន០១កញ្ចប់ ទម្ងន់ 0,២២ក្រាម (សូន្យក្បៀសម្ភៃពីរក្រាម)។

**ត្រូវរឹបអូស និងបំផ្លាញចោល។**

-ម៉ូតូចំនួន០១គ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1AE-4741។

**ត្រូវប្រគល់ឱ្យម្ចាស់វិញ។**

៤/.បញ្ឈប់ការចាប់ខ្លួនលើឈ្មោះ [redacted] ថារដ្ឋ ហៅ ទុន ភេទប្រុស កើតឆ្នាំ២០០៨ ជនជាតិខ្មែរ តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខៈ ១៣០ /ត.ព្រ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។

៥/.បង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ ហៅ ទុន ដោយអនុវត្តតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់វាសនា ហៅ ស្នា និងឈ្មោះ [redacted] ទុំ, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ថារដ្ឋ ហៅ ទុន និងប្រកាសជាអសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

ទុកសិទ្ធិប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តតាកែវ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner